ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក

PROCEDURES FOR MANAGEMENT REVENUES AND EXPENSE OF RMA (CAMBODIA) PLC.

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

## នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ រិម អេ (ខេមបូឌា) ម.ក

## PROCEDURES FOR MANAGEMENT REVENUES AND EXPENSE OF RMA (CAMBODIA) PLC.

គ្រូណែនាំ៖ កុសល់ សឿន

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទៈ នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ**
**(ខេមបូឌា) ម.ក**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

កុសល់ សឿន

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើ ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថា ជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្ដី ឯកជនក្ដី ឬអង្គការក្រៅរដ្ឋាភិបាលក្ដីសុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយរហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្ដើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្ដល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយត បឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្ដីពី **"នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រង ក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះឡើងនឹងបានចូលរួមចំណែកមួយ ក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀត ដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**ផល្លី ធីតា**
ID: B22/1633



**ភុន ស្រីណាក់**
ID: B22/1644



**យុន ទ្រឹម**
ID: B22/959



**ទូលាស់ ហ្វានី**
ID: B22/1579



**ថៃ៉ លីសា**
ID: B22/1048

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **កុសល់ សឿន** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដា ទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២ៈ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី "**នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក**" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩.... ខែតុលាឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

ផល្លី ធីតា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

RMA (Cambodia) Plc.គឺជាក្រុមហ៊ុនចំណូលចិត្តដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៩២។ ក្រុមហ៊ុនបានពង្រីកអាជីវកម្មរបស់ខ្លួនក្នុងវិស័យផ្សេងៗដូចជា យានយន្ត កសិកម្ម ឧបករណ៍ធុនធ្ងន់ សេវាកម្មហិរញ្ញវត្ថុ និងម្ហូបអាហារ។ ក្រុមហ៊ុនមានសិទ្ធិផ្តាច់មុខក្នុងការនាំចូលម៉ាកយានយន្តដូចជា FORD, JAGUAR LAND ROVER, និង FUSO។ ក្រុមហ៊ុនក៏មានរោងចក្រដំឡើងរថយន្ត FORD នៅខេត្តពោធិ៍សាត់ និងផ្តល់សេវាជួលរថយន្តតាមរយៈក្រុមហ៊ុន AVIS និង Budget។ ក្រុមហ៊ុនក៏មានក្រុមហ៊ុនផ្តល់សេវាហិរញ្ញវត្ថុ BSP Finance ដែលផ្តល់ជូនដំណោះស្រាយហិរញ្ញវត្ថុសម្រាប់យានយន្ត និងឧបករណ៍ផ្សេងៗ។

ក្នុងរយៈពេលចុងក្រោយ RMA បានបង្ហាញពីការរីកចម្រើនសេដ្ឋកិច្ចដ៏ល្អ។ ក្នុងឆ្នាំ២០២២ ក្រុមហ៊ុនបានរាយការណ៍ថាមានប្រាក់ចំណូលសរុប ២.២០៣ ពាន់លានរៀល និងប្រាក់ចំណេញសរុប ២៤៧.៦៦៩ ពាន់លានរៀល ដែលបង្ហាញពីការកើនឡើងប្រមាណ ៣៥.៤៦% និង ៥៥.៩១% បើប្រៀបធៀបនឹងឆ្នាំ ២០២១។ ទោះបីជាការសេដ្ឋកិច្ចមានការធ្លាក់ចុះក្នុងត្រីមាសទី៤ ឆ្នាំ២០២៣ ក្រុមហ៊ុនក៏បានបង្ហាញពីការធ្លាក់ចុះក្នុងប្រាក់ចំណូល ៥៣% និងការបាត់បង់ប្រាក់ចំណេញ១៣.១ ពាន់លានរៀល ប៉ុន្តែទ្រព្យសកម្មសរុបនៅចុងឆ្នាំ ២០២៣ បានកើនឡើង ២៣% ទៅ ១.០៩៤ ពាន់លានរៀល ។ ហើយក្រុមហ៊ុនក៏បានទទួលសញ្ញាបត្រពីការអនុវត្តតាមបទបញ្ញារដ្ឋបាលពន្ធប្រាក់ចំណូលប្រចាំឆ្នាំ២០២៤-២០២៥ ពីនាយកដ្ឋានពន្ធដារជាតិកម្ពុជា ។ បន្ថែមពីលើការពង្រីកអាជីវកម្ម ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក ក៏បានផ្តោតការយកចិត្តទុកដាក់លើធនធានមនុស្ស តាមរយៈការផ្តល់កម្មសិក្សា និងឱកាសការងារដល់បុគ្គលិកក្នុងស្រុក និងវិជ្ជាជីវៈប្រមាណ ៣០០០ នាក់ ជាមួយនឹងជនបរទេសមួយចំនួនដែលធ្វើការរួមគ្នាដើម្បីចែករំលែកជំនាញ និងជំនាញរបស់ពួកគេ។ RMA Cambodia ក៏មានសកម្មភាពយ៉ាងខ្លាំងជាមួយសហគមន៍មូលដ្ឋាន។ យើងសហការគ្នាជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការនានា ដើម្បីផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងវិស័យសំខាន់ៗ ដូចជា សុខភាព បរិស្ថាន ការអប់រំ និងកីឡា។

សរុបមក RMA (Cambodia) Plc.គឺជាក្រុមហ៊ុនដែលមានឥទ្ធិពលខ្ពស់ក្នុងវិស័យសេដ្ឋកិច្ចនៃប្រទេសកម្ពុជា និងមានការរីកចម្រើនយ៉ាងច្បាស់ក្នុងការអភិវឌ្ឍអាជីវកម្ម និងការអនុវត្តតាមបទបញ្ញារដ្ឋបាល។

# មាតិកា

ទំព័រ

អារម្ភកថា ........ i
រចនាសម្ព័នក្រុម ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
 ១.៤.១ ទំហំដែនកំណត់ ........ ២
 ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២
 ១.៥.១ វិធីសាស្រ្តដែលបានយកមកប្រើប្រាស់ក្នុងការសរសេរសារណា ........ ២
 ១.៥.២ ការប្រមូលទិន្នន័យ ........ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ២
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២
## នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន

២.១ លក្ខណៈទូទៅនៃនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន
 ២.១.១ និយមន័យនៃការគ្រប់គ្រង ........ ៤
 ២.១.២ ប្រវត្តិនៃការគ្រប់គ្រង ........ ៤
 ២.១.៣ ទ្រឹស្តីនៃការគ្រប់គ្រង ........ ៥
 ២.១.៤ តួនាទីនៃការគ្រប់គ្រង ........ ៦
២.២ ប្រភពចំណូល និងប្រភេទចំណាយសំខាន់ៗរបស់ក្រុមហ៊ុន ........ ៧
 ២.២.១ និយមន័យនៃចំណូល ........ ៧
 ២.២.២ ប្រវត្តិនៃចំណូល ........ ៧
 ២.២.៣ ទ្រឹស្តីនៃចំណូល ........ ៨

២.៣ នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន
២.៣.១ និយមន័យនៃនីតិវិធី ........ ៨
២.៣.២ ប្រវត្តិនៃនីតិវីធី ........ ៨
២.៣.៣ ទ្រឹស្តីនៃនីតិវីធី ........ ៩
២.៣.៤ មុខងារនៃនីតិវីធី ........ ១០

## ជំពូកទី៣
## នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក

៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ........ ១២
៣.១.២ ទីតាំងរបស់ក្រុមហ៊ុន ........ ១៤
៣.១.៣ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ........ ១៤
៣.១.៤ គោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ........ ១៤
៣.១.៥ ទស្សនៈវិស័យ បេសកកម្ម គោលដៅ និងមុខងារ ........ ១៥
៣.១.៦ អាជីវកម្មដៃគូ ........ ១៨
៣.១.៧ ច្បាប់អនុវត្តន៍ក្នុងក្រុមហ៊ុនអាជីវកម្ម ........ ១៨
៣.២ យុទ្ធសាស្ត្របង្កើនចំណូល និងគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធិភាពខ្ពស់
៣.២.១ យុទ្ធសាស្ត្របង្កើនចំណូល ........ ១៩
៣.២.២ យុទ្ធសាស្ត្រការគ្រប់គ្រងចំណាយ និងប្រើប្រាស់ឱ្យមានប្រសិទ្ធិភាព ........ ២១
៣.២.៣ ការវិភាគចំណូល និងចំណាយ ........ ២២
៣.៣ នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក
៣.៣.១ នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន
ក. នីតិវិធីក្នុងការគ្រប់គ្រងចំណូល ........ ២២
ខ. នីតិវិធីក្នុងការគ្រប់គ្រងចំណាយ ........ ២៣
៣.៣.២ ការគ្រប់គ្រងចំណូល និងចំណាយតាមប្រព័ន្ធគណនេយ្យ ........ ២៤
៣.៣.៣ ផលប្រយោជន៍នៃការគ្រប់គ្រងចំណូល និងចំណាយ ........ ២៥

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........ ២៦
៤.២ ការវិភាគលើចំណុចខ្សោយ ........ ២៦

## ជំពូកទី៥
## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................................................................ ២៧
៥.២ ការផ្តល់អនុសាសន៍ ........................................................................................ ២៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា បានឆ្លាប់ឆ្លងកាត់ដំណាក់កាលប្រវត្តិសាស្ត្រជាច្រើន ដែលបណ្តាលឱ្យប្រទេសមួយនេះ ជួបវិបត្តិនយោបាយជាច្រើនលើកច្រើនសារ។ ក្រោយពីទទួលបានជ័យជម្នះក្រោមស្នាដៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន** នូវនយោបាយឈ្នះៗ ទើបប្រទេសកម្ពុជាទទួលបាននូវសន្តិភាពពេញលេញ។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាយើងមានការរីកចម្រើនស្ទើរតែគ្រប់វិស័យដូចជា វិស័យអប់រំ វិស័យសុខាភិបាល វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យពាណិជ្ជកម្មជាដើម...។ ក្នុងនោះវិស័យពាណិជ្ជកម្ម បានជួយជំរុញសេដ្ឋកិច្ចឱ្យកាន់តែមានភាពរីកចម្រើនឡើង។ ស្របពេលនេះផងដែរ មាននិនិយោគិនជាច្រើន បានមកធ្វើការវិនិយោគដោយទទួលបានជោគជ័យគួរឱ្យកត់សម្គាល់។ ភាពជោគជ័យនេះ កើតឡើងដោយសារកត្តាជាច្រើន ជាពិសេសគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ ដែលសំដៅដល់ការគ្រប់គ្រងចំណូល និងចំណាយ អាចធានាបាននូវនិរន្តរភាពនៃដំណើរការរបស់ក្រុមហ៊ុន។

ការគ្រប់គ្រងចំណូល និងចំណាយមានសារៈសំខាន់ណាស់ ព្រោះវាធ្វើឱ្យក្រុមហ៊ុន ឬអង្គភាពអាចដោះស្រាយបញ្ហា ឬទប់ស្កាត់នូវហានិភ័យបានទាន់ពេលវេលា នៅពេលដែលក្រុមហ៊ុនជួបនូវវិបត្តិហិរញ្ញវត្ថុ។ ការគ្រប់គ្រងចំណូល និងចំណាយបានត្រឹមត្រូវអាចជួយឱ្យក្រុមហ៊ុនកសាងភាពរឹងមាំ និងងាយស្រួលក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារបច្ចុប្បន្ន។ ប្រសិនបើ ក្រុមហ៊ុនគ្មានគោលនយោបាយ ឬនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយឱ្យបានត្រឹមត្រូវទេ នោះក្រុមហ៊ុនមិនអាចមានការរីកចម្រើនបានឡើយ។ម្យ៉ាងវិញទៀត ការគ្រប់គ្រងចំណូល និងចំណាយក៏ជាផ្នែកមួយដែលបានជួយជំរុញល្បឿននៃការរីកចម្រើនរបស់ក្រុមហ៊ុនផងដែរ។

ការរីកចម្រើនរបស់ក្រុមហ៊ុន គឺអាស្រ័យលើប្រព័ន្ធក្នុងការគ្រប់គ្រង ឬនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយបានត្រឹមត្រូវ ប្រសិនបើក្រុមហ៊ុនមិនមានការគ្រប់គ្រងចំណូល និងចំណាយឱ្យបានត្រឹមត្រូវទេ នោះនឹងផ្តល់ផលប៉ះពាល់ដល់ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនជាមិនខាន។ ហេតុដូច្នេះហើយ ទើបក្រុមនាងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយស្តីពី **"នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក"** យកមកសិក្សាស្រាវជ្រាវ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃនេះ បណ្តាលក្រុមហ៊ុនពាណិជ្ជកម្មជាច្រើនកំពុងរីកចម្រើននៅក្នុងប្រទេសកម្ពុជា ប៉ុន្តែយ៉ាងណាមិញ យើងសង្កេតឃើញថាក្នុងការគ្រប់គ្រងក្រុមហ៊ុនមួយឱ្យបានជោគជ័យ អ្នកគ្រប់គ្រងក្រុមហ៊ុនបានរៀបចំវិធីសាស្ត្រ និងយុទ្ធសាស្ត្រល្អៗបំផុតក្នុងការគ្រប់គ្រងក្រុមហ៊ុន ដោយវិភាគទៅលើការគ្រប់គ្រងចំណូល និងចំណាយជាចម្បងក្នុងគោលបំណងធ្វើយ៉ាងណាទទួលបានប្រសិទ្ធិភាពខ្ពស់ក្នុងការទាញយកចំណូល។

ហេតុដូច្នេះហើយ ទើបក្រុមនាងខ្ញុំមានសំណួរមួយចំនួនចោទសួរដូចខាងក្រោម៖

១.តើក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក មានយុទ្ធសាស្ត្របែបណាក្នុងការបង្កើនចំណូល និងគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធភាពខ្ពស់?

២.តើក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក មាននីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយយ៉ាងដូចម្តេច?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលបំណងសំខាន់គឺផ្តោតទៅលើការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក ដែលលើកមកស្វែងយល់បន្ថែមរួមមានដូចជា៖

- ស្វែងយល់ពីយុទ្ធសាស្រ្តបង្កើនចំណូល និងគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន
- ស្វែងយល់ពីនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំនិងដែនកំណត់

ការស្រាវជ្រាវនេះ មានគោលបំណងសំខាន់ផ្តោតទៅលើការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ២៧ ផ្លូវ ១៣៤ ប្រអប់សំបុត្រ៥៥ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។ យើងផ្តោតសំខាន់ការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺផ្តោតទៅលើការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក នៅឆ្នាំ២០២២-២០២៣ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យ ដោយផ្តោតចម្បងទៅលើការវិភាគទិន្នន័យ និងឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់អំពី នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្តាញសង្គមរបស់ក្រុមហ៊ុនផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវ ឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍ ចាស់ៗដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្តាញសង្គមរបស់ក្រុមហ៊ុនផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវឯកសារមេរៀនទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗរបាយការណ៍ចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងការស្រាជ្រាវនេះដែរ គឺបានផ្តល់សារៈសំខាន់ជាច្រើនដល់ក្រុមនាងខ្ញុំនឹងអ្នកដែលមានតម្រូវការទិន្នន័យដែលទាក់ទងប្រធានបទផងដែរ។ ក្រោយពីការស្រាវជ្រាវយើងទទួលបាននូវ៖

**សម្រាប់ស្ថាប័ន៖** យល់ដឹងពីយុទ្ធសាស្ត្រក្នុងការប្រកួតប្រជែងជាមួយដៃគូដទៃទៀត ដើម្បីងាយស្រួលបំពេញទៅតាមតម្រូវការរបស់អតិថិជន និងការអនុវត្តការងារជាក់ស្តែងនៅក្នុងក្រុមហ៊ុន

**សម្រាប់សង្គម៖** ជាឯកសារជំនួយដើម្បីជាប្រយោជន៍ដល់សិស្សនិស្សិត យកទៅសិក្សាបន្តនិងទទួលបានចំណេះដឹងបន្ថែមពីឯកសារទាំងនេះ និងអ្នកស្រាវជ្រាវជំនាន់ក្រោយ

**សម្រាប់កម្មសិក្សាការី៖** បង្កើនចំណេះដឹងនិងការយល់ដឹងបន្ថែមដែលផ្សារភ្ជាប់ជាមួយប្រធាន ដែលបានសិក្សា។ ម្យ៉ាងវិញទៀតបង្កើនភាពក្លាហានដល់ក្រុមសិក្សាស្រាវជ្រាវក្នុងការបញ្ចេញមតិផ្សេងៗ និងដឹងពីសកម្មភាព រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ក្រុមហ៊ុនផងដែរ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានបែងចែកជាប្រាំជំពូកដូចខាងក្រោម៖ ក្នុងការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានបែងចែកជាប្រាំជំពូកដូចខាងក្រោម៖

**ជំពូកទី១ សេចក្តីផ្តើម**

➢បង្ហាញគំនិតផ្តួចផ្តើមដែលទាក់ទងនិងទិដ្ឋភាព បុព្វហេតុ ឬវត្ថុបំណងដែលបង្ហាញពីអត្ថប្រយោជន៍ នៃការស្រាវជ្រាវ។

**ជំពូកទី២ រំលឹកទ្រឹស្តី**

➢នៅក្នុងជំពូកនេះមានការបកស្រាយបំភ្លឺពីនិយមន័យទ្រឹស្តី នឹងឯសារដែលពាក់ព័ន្ធនិងការរៀបចំគម្រោងចំណូល និងចំណាយរបស់ក្រុមហ៊ុន។

**ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ**

➢នៅជំពូកនេះមានការបកស្រាយពីលក្ខណៈទូទៅរបស់ក្រុមហ៊ុន ប្រវត្តិរបស់ក្រុមហ៊ុននិង គោលការណ៍ព្រមទាំងរចនាសម្ព័ន្ធ ហើយក៏ជាចម្លើយដែលត្រូវឆ្លើយតបទៅនឹងសំនួរបានស្រាវជ្រាវទាំងពីរ ខាងលើរបស់ក្រុមហ៊ុនយើងខ្ញុំ បានធ្វើការចោតសួរហើយក៏ជាផ្នែកមួយដើរទន្ទឹមគ្នានឹងគោលបំណងនៃការ ស្រាវជ្រាវ។

**ជំពូកទី៤ ការវិភាគលើចំណុចខ្លាំង និង ចំណុចខ្សោយ**

➢ជំពូកនេះមានការបង្ហាញពីការវិភាគទៅលើចំណុចខ្លាំង និងចំណុចខ្សោយនៃការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន។

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន ការផ្តល់អនុសាសន៍**

➢ជំពូកនេះមានការបង្ហាញពីការធ្វើសំយោគទៅលើចំណុចសំខាន់ៗទាក់ទងទៅនិង ការគ្រប់គ្រងចំណូលនិងចំណាយរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ព្រមទាំងអនុសាសន៍កែលម្អពីលើខ្លះៗ។

# ជំពូកទី២
# នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន

## ២.១ លក្ខណៈទូទៅនៃនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន

### ២.១.១ និយមន័យនៃការគ្រប់គ្រង

➢ការគ្រប់គ្រង(Management) គឺជាដំណើរការនៃការប្រើប្រាស់ធនធាន នៅក្នុងអង្គភាពឱ្យទទួលបានជោគជ័យដល់អង្គភាព ដោយមានការរៀបចំ ការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យ[1]។

➢ការគ្រប់គ្រង(Management) គឺជាដំណើរការរៀបចំចាត់តែងដឹកនាំនិងត្រួតពិនិត្យដោយប្រើធនធានផ្សេងៗទៀតដើម្បីសម្រេចគោលដៅ [2]។

➢ការគ្រប់គ្រង(Management) គឺជាដំណើរការធ្វើ ផែនការ ការចាត់តាំង ដឹកនាំ និងត្រួតពិនិត្យលើការប្រើប្រាស់ធនធានមនុស្ស និងធនធានដទៃទៀតដើម្បីសម្រេចនូវគោលដៅអង្គភាព ដោយមានប្រសិទ្ធិភាពខ្ពស់បំផុត។

➢ការគ្រប់គ្រង គឺជាដំណើរការលើការទាក់ទង ទៅលើបណ្ដាញការងារយ៉ាងស្មុគស្មាញរវាងមនុស្សនិងមនុស្ស ជាមួយធនធានផ្សេងៗទៀត[3]។

➢ការគ្រប់គ្រង(Management) គឺជាដំណើរការនៃការធ្វើការជាមួយនឹងមនុស្សនិងធនធានដទៃទៀតដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព[4]។

➢ការគ្រប់គ្រង(Management) គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្រ្ត ដែលសិក្សាលម្អិតអំពី៖ ១.ការធ្វើផែនការ(Planning) ២.ការចាត់ចែង (Organizing) ៣.ការដឹកនាំ (Leading) ៤.ត្រួតពិនិត្យឡើងវិញ (Controlling) និង ៥.ការធ្វើសេចក្តីសម្រេចចិត្ត (Decision making)[5]។

➢ការគ្រប់គ្រង គឺជាដំណើរការនៃការធ្វើផែនការ ចាត់តាំង ដឹកនាំ និងត្រួតពិនិត្យ លើការប្រើប្រាស់ធនធានមនុស្ស និងធនធានដទៃទៀត ដើម្បីសម្រេចគោលដៅរបស់អង្គការ ចាត់តាំងឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត [6]។

➢ការគ្រប់គ្រង គឺជាដំណើរការមួយនៃអង្គការចាត់តាំងមួយដែលមានប្រសិទ្ធភាព[7]។

---

[1] KHsearch. គ្រប់គ្រង. (2019, September 05). *ការគ្រប់គ្រង*. Retrieved February, 02 2025 from https://www.khsearch.com/qna/24819

[2] KHsearch. ហ៊ូ សម្ផស្ស. (2018, September 21). *ការគ្រប់គ្រង*. Retrieved February, 02 2025 from https://www.khsearch.com/qna/7930

[3] TVETកម្ពុជា. (2019, February 20). *ការគ្រប់គ្រង*. Retrieved February, 02 2025 from https://www.tvet-elearning.com/home/course/618c82e35d8dee33c76e2fbe

[4] Facebook Page. គង់ ឆាយឡុង. (2021, April 18). *ការគ្រប់គ្រង*. Retrieved February, 02 2025 from https://www.facebook.com/photo/?fbid=1044111312782325&set=pcb.1044102736116516

[5] វិទ្យាស្ថានវ៉ាន់ដា. (២០១៧). *មូលដ្ឋានគ្រឹះនៃការគ្រប់គ្រង*. បោះពុម្ពលើកទី៦. ទំព័រទី២. ភ្នំពេញ

[6] HR and Training Solution. (April, 18 2021). *ការគ្រប់គ្រង*. Retrieved February, 03 2025 from https://www.facebook.com/hrtrainingsolution/posts/លក្ខណៈទូទៅនៃការគ្រប់គ្រង-nature-of-management/1647883315421338/

[7] រៀបរៀងដោយនិស្សិត ម៉េស ស្រីម៉ៅ, អ៊ុំ រ៉ាមី, ហេង សុផាវ៉ាន់, រិន សៀមី. (2022). *ការគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន ប៉ា ស៊ី ហ្វិក កុំព្យូទ័រ*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី១៩. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៥. ៣០ទំព័រ. ភ្នំពេញ។

➢ការគ្រប់គ្រងគឺជាការទទួលខុសត្រូវមួយដ៏លំបាកវាទាមទារឲ្យអ្នកគ្រប់គ្រងចាំបាច់ត្រូវមានសមត្ថភាពយល់ដឹងខ្ពស់រហ័សរហួនប្រកបដោយភាពប៉ិនប្រសព្វនឹងមានចំណេះដឹងធំទូលាយបើទោះបីជាយ៉ាងនេះក៏ដោយក៏នៅ មានអ្នកគ្រប់គ្រងខ្លះទទួលបានជោគជ័យហើយអ្នកគ្រប់គ្រងបរាជ័យផងដែរ[8]។

**២.១.២ ប្រវត្តិនៃការគ្រប់គ្រង**

ពាក្យនេះ វាអាចមានអត្ថន័យទូលំទូលាយខ្លាំង រហូតដល់យើងពិបាកនៅក្នុងការកំណត់វាឱ្យបានច្បាស់លាស់។ បើយើងធៀបវាពីសម័យបុរេប្រវត្តិបុរាណប្រវត្តិសាស្ត្រ និងបច្ចុប្បន្ននៃសម័យបច្ចេកវិទ្យាការគ្រប់គ្រងនៅតែមាននឹងមានរហូតដល់ការគ្រប់គ្រងនៃវត្ថុមានតម្លៃផ្សេងៗទៀតជាច្រើន។ នៅសម័យបុរេប្រវត្តិមនុស្សមានការរស់នៅជាក្រុម នឹងមានអ្នកគ្រប់គ្រងតែម្នាក់ទ្រព្យសម្បត្តិ ដែលពួកគេមានទុកដូចជារបស់រួមគ្មានកម្មសិទ្ធិរបស់បុគ្គលម្នាក់ណានោះទេ គឺមានតែមេកន្ទ្រាញរបស់ពួកគេជាអ្នកចាត់ចែង។ នៅក្នុងសម័យបុរាណប្រវត្តិសាស្ត្រការគ្រប់គ្រងមនុស្សកាន់តែតឹងរឹង ពួកគេបានបង្កើតនូវក្បួនច្បាប់នានា ដើម្បីគ្រប់គ្រងយើងអាចនិយាយបានថាវាគឺជាសម័យកាលនៃការស្វែងរកអំណាចឥទ្ធិពលដើម្បីគ្រប់គ្រងមនុស្ស។ ច្បាប់ទាំងនោះវាត្រូវបានបង្កើតឡើង ទៅតាមប្រភេទនៃការរស់នៅរបស់ក្រុមមនុស្ស នឹងឥរិយាបថដែលពួកគេមាន ឬយើងនិយាយបានថាវាបានក្លាយទៅជាវប្បធម៌ប្រពៃណី នៃក្រុមមនុស្សទាំងនេះលើសពីនេះការគ្រប់គ្រងទៅលើទ្រព្យសម្បត្តិ មាសប្រាក់ ការវិនិយោគក៏ត្រូវបានបង្កើតឡើងព្រមគ្នាផងដែរ។

នៅក្នុងសម័យបច្ចុប្បន្ន នៃបច្ចេកវិទ្យាក៏នៅមានគ្រប់គ្រងមនុស្ស និងការគ្រប់គ្រងនូវទ្រព្យសម្បត្តិនានាផងដែរ គ្រាន់តែវាមាននៅលក្ខណៈពិសេស គឺវាត្រូវបានផ្តោតនៅសេរីភាព ឯកកម្មសិទ្ធិវត្ថុច្រើនជាងសម័យបុរេប្រវត្តិសាស្ត្រ និងសម័យកាលបុរាណប្រវត្តិវិទ្យាភាពរីកចម្រើននៃការគ្រប់គ្រង ត្រូវបានផ្តោតសំខាន់ទៅតាម សម័យកាលឧស្សាហកម្មទំនើប វាត្រូវបានបែងចែក ដាច់ដោយឡែក ទាំងការគ្រប់គ្រងមនុស្ស ទ្រព្យសម្បត្តិ សកម្មភាពអាជីវកម្មអង្គភាព សកម្មភាពមុខជំនួញ ការគ្រប់គ្រងវិន័យដែលវាសុទ្ធតែត្រូវបានបង្កើតឡើងទៅតាមបរិបទប្រទេស អង្គភាព ស្ថាប័នអង្គភាពមុខជំនួញអាជីវកម្ម និងរបៀបនៃការរស់ នៅរបស់មនុស្សផ្សេងៗគ្នា។ ជាពិសេស វាក៏ត្រូវបានធ្វើការឆ្លើយតបភ្លាមៗ ទៅតាមការប្រតិកម្មនៃក្រុមមនុស្ស អង្គភាពស្ថាប័ន ឬប្រទេសណាមួយនៅក្នុងករណីពិសេសណាមួយ ឬបញ្ហាណាមួយដែលត្រូវបានចោទឡើង នៅពេលដែលការ គ្រប់គ្រងមានចន្លោះខ្វះខាត ដែលបណ្តាលមកពីកំហុសបច្ចេកទេសណាមួយ ដែលបានបង្កើតនៃអ្នកគ្រប់គ្រងដែលងាយនឹងបង្កហានិភ័យដល់អង្គភាពស្ថាប័ន ឬប្រទេសណាមួយដែលបង្កឱ្យមានជាហានិភ័យដែលប៉ះពាល់ខ្លាំងដល់វដ្តជីវិតហិរញ្ញវត្ថុ។

បច្ចុប្បន្នភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ គឺវាស្ថិតនៅក្នុងភាពចាំបាច់ពិសេសត្រូវធ្វើវាឱ្យមានតម្លាភាពដើម្បីរក្សាស្ថេរភាពហិរញ្ញវត្ថុនៅក្នុងអង្គភាពស្ថាប័ន និងជាពិសេសគឺដើម្បីតម្លៃហិរញ្ញវត្ថុប្រទេស នីមួយៗនៅលើពិភពលោក ព្រោះថាការបាត់បង់តម្លៃហិរញ្ញវត្ថុប្រៀបដូចជាការបាត់បង់តម្លៃនៃប្រទេសជាតិ ទាំងមូលដោយសារតែតម្លៃនៃហិរញ្ញវត្ថុវាបានបង្ហាញអំពីដំណើរការល្អរបស់ជាតិ សេដ្ឋកិច្ច និងសង្គមជាតិទាំងមូល[9]។

---

[8] រៀបរៀងដោយនិស្សិត ផៃ ប៊ុនម៉ា, មាស សៀវឡាន, នួន ម៉ាទិត្យ, កៅ ឧស្សាហ៍, សន សេងហួរ (2022). *ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុន អិនវីស៊ី ខបភើរេសិន ខូអិលធីឌី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី១៩. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៧. ៣៦ទំព័រ. ភ្នំពេញ។

[9] Science direct. Social Sciences. (2015). *History of Management*. Retrieved February, 03 2025 from https://www.sciencedirect.com/topics/social-sciences/history-of-management#:~:text=The%20'History%20of%20Management'%20refers,in%20various%20sectors%20and%20organizations.

### ២.១.៣ ទ្រឹស្តីនៃការគ្រប់គ្រង

➢ទ្រឹស្តីវ៉ាយ (Theory Y)

➢អ្នកគ្រប់គ្រងទទួលខុសត្រូវចំពោះការចាត់ចែងកិច្ចការទាំងឡាយ នៃសហគ្រាសផលិតរួមមាន ប្រាក់ សម្ភារៈ គ្រឿងបរិក្ខារ មនុស្ស ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច។

➢អាស្រ័យដោយមនុស្សទាំងឡាយរមែងត្រូការការសរសើរ ការលើកទឹកចិត្ត គេក៏មានសក្តានុពលភាពនូវការអភិវឌ្ឍ អាចទទួលយកបាននូវការទទួលខុសត្រូវ និងឆន្ទៈធ្វើការឆ្ពោះទៅរកគោលបំណងនៃអង្គការចាត់ចែងនេះ ។

➢ភារកិច្ចជាសារវន្តនៃការគ្រប់គ្រងគឺត្រូវរៀបចំលក្ខខណ្ឌនៃអង្គភាព និងវិធីប្រតិបត្តិដើម្បីឱ្យការងារមានដំណើរឆ្ពោះទៅរកគោលដៅរបស់អង្គភាព ក្នុងក្របខ័ណ្ឌជាមធ្យោបាយដ៏ល្អបំផុតសម្រាប់បុគ្គលសម្រេចគោលបំណងផ្ទាល់ខ្លួនរបស់គេ ។

➢ទ្រឹស្តីអ៊ិច 19 (Theory X)

➢អ្នកគ្រប់គ្រងទទួលខុសត្រូវចំពោះការចាត់ចែងកិច្ចការទាំងឡាយនៃសហគ្រាសផលិតកម្ម រួមមានថវិកា សម្ភារៈ គ្រឿងបរិក្ខារ មនុស្សគឺក្របខ័ណ្ឌផលប្រយោជន៍ នៃភាពសន្សំសំចៃសេដ្ឋកិច្ចតែមួយប៉ុណ្ណោះ។

➢មុខងាររបស់អ្នកគ្រប់គ្រង គឺជាការលើកទឹកចិត្តដល់កម្មករ ដឹកនាំការខិតខំរបស់គេត្រួតពិនិត្យសកម្មភាពរបស់គេ និងផ្លាស់ប្តូរអាកប្បកិរិយារបស់គេដើម្បីសម្រេចឱ្យត្រូវតាមតម្រូវការរបស់អង្គភាពចាត់ចែង។

➢ទ្រឹស្តីលោក Frederick W.Talor

លោក Frederick W.Talor បានកំណត់ច្បាស់លាស់ឱ្យអ្នកគ្រប់គ្រងទាំងអស់គួរតែ៖

➢ត្រូវបានបណ្តុះបណ្តាលលើគោលការណ៍វិទ្យាសាស្ត្រ

➢ត្រូវសិក្សាកិត្យានុភាពក្នុងការគ្រប់គ្រង

➢ត្រូវចេះបែងចែកការងារឱ្យបានច្បាស់លាស់រវាងអ្នកគ្រប់គ្រង និងកម្មករ

➢ការជ្រើសរើស និងបណ្តុះបណ្តាលកម្មករទៅតាមជំនាញរបស់គេ

➢មានការលើកទឹកចិត្តល្អ និងជាគំរូល្អដល់កម្មករ

➢ត្រួតពិនិត្យនរណាម្នាក់ដោយពុំប្រើអំណាចផ្តាច់ការ

➢បើគ្មានអន្តរាគមន៍សកម្មភាពបែបនេះរបស់អ្នកគ្រប់គ្រងមនុស្សទាំងឡាយអាចប្រែទៅជាអសកម្ម ឬប្រឆាំងតទល់នឹងតម្រូវការរបស់អង្គភាពចាត់ចែង ។

➢ទ្រឹស្តីលោកអាដាម ស្មីធ(Adam Smith)

លោកAdam Smith បានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការគ្រប់គ្រង(Managenet) ពោលគឺ៖

➢ការរៀបចំជាគម្រោងឱ្យបានម៉ត់ចត់(Planning)

➢ការរៀបចំចាត់ចែង(Oganize)

➢ការដឹកនាំ(Leading)

➢ការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ(Controlling)[10]។

### ២.១.៤ តួនាទីនៃការគ្រប់គ្រង

➢តួនាទីអន្តរៈបុគ្គល ជាអ្នកតំណាង ជាអ្នកដឹកនាំ និងមានតួនាទីទំនាក់ទំនង។

➢តួនាទីព័ត៌មាន ប្រមូលព័ត៌មានពីស្ថាប័នខាងក្រៅ តាមដានត្រួតពិនិត្យព័ត៌មាន និងការផ្សព្វផ្សាយ និងមានតួនាទីជាអ្នកនាំពាក្យ។

➢តួនាទីធ្វើការសម្រេចចិត្ត គឺជាតួនាទីចុងក្រោយរបស់អ្នកគ្រប់គ្រងដែលបានកំណត់តួនាទីនោះជា៤ គឺ តួនាទីជាសហគ្រិន តួនាទីជាអ្នកដោះស្រាយ បែងចែកធនធាន និងតួនាទីចរចារ[11] ។

## ២.២ យុទ្ធសាស្ត្របង្កើនចំណូល និងគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធិភាពខ្ពស់

### ២.២.១ និយមន័យនៃចំណូល

➢ចំណូល គឺជាការកើនឡើងនៃទ្រព្យសកម្ម ទោះបានមកពីប្រភពប្រត្តិបត្តិការអាជីវកម្ម ការផ្តល់មូលនិធិ ឬបានពីស្ថាប័នណាក៏ដោយ សុទ្ធតែជាចំណូលទាំងអស់[12]។

➢ចំណូល គឺជាតួលេខសរុបមួយដែលរកបាន ពីការលក់ផលិតផល ឬសេវាកម្មដែលជាប់ទាក់ទងនឹងប្រតិបត្តិការនៃក្រុមហ៊ុន។ ចំណូលតែងតែត្រូវបានគេសរសេរនៅលើគេនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ[13]។

➢ចំណូល គឺជាការហូរចូល ឬជាការរីកចម្រើននៃទ្រព្យរបស់អង្គភាព។ វាកើតឡើងនៅពេលដែលយើងទទួលសាច់ប្រាក់ពីការទិញ លក់ទំនិញ ឬសេវានានា[14]។

### ២.២.២ ប្រភេទនៃចំណូល

នៅក្នុងស្ថាប័ននៃសហគ្រាស និងស្ថាប័នមិនស្វែងរកប្រាក់ចំណេញ ត្រូវមានប្រតិបត្តិការចំណូល ដើម្បីប្រតិបត្តិការនៅក្នុងអង្គភាពនេះដើម្បីមានដំណើរការ និង អាចវាស់វែងពីដំណើរការសេដ្ឋកិច្ចទាំងនេះ។ ប្រាក់ចំណូលដែលរកបានច្រើនតែត្រូវបានគេហៅថាជាប្រាក់ខែ។ ចំណូលអាចទទួលបានពីប្រភពផ្សេងៗគ្នាគឺ៖

➢ការលក់ទំនិញ ឬផលិតផល គឺជាចំណូលដែលបានមកពីការងារលក់ផលិតផលរបស់ក្រុមហ៊ុន និងទទួលជាប្រាក់ចំណេញដុលដែលមិនទាន់ទូទាត់ជាមួយថ្លៃដើមនៃទំនិញ។

➢ប្រាក់ចំណូលពីការផ្តល់សេវាកម្មលើការបង់រំលស់ ជួសជុល ផ្លាស់ប្តូរគ្រឿងបន្លាស់ សេវាថែទាំរថយន្ត ផ្តល់ប្រឹក្សាយោបល់ ការដឹកជញ្ជូន សម្រាប់ស្ថានភាពអាជីវកម្មនៃសេវាកម្មត្រូវបានទទួលចំណូលតាមរបៀបផ្សេងៗគ្នាគឺការទទួល។ ចំណូលមុនមិនទាន់បានផ្តល់សេវាកម្មដូចជាការបង់ចំណូលកម្រៃ

[10] Facebook Page. Banalai Neakhttps. (2020, July 26). *ទ្រឹស្តីនៃការគ្រប់គ្រង*. Retrieved February, 05 2025 from https://www.facebook.com/banalaineak/posts/ទ្រឹស្តីនៃការគ្រប់គ្រង-modern-theory-of-management/167329684831908/

[11] KHsearch. ចំណេះដឹងទូទៅគ្រប់គ្រង. (2018, September 27). *តួនាទីនៃអ្នកគ្រប់គ្រង*. Retrieved February, 05 2025 from https://www.khsearch.com/qna/8189

[12] Investopedia. Adam Hayes. (2023, October 19). *Revenues*. Retrieved February, 05 2025 from https://www.investopedia.com/terms/r/revenue.asp?utm_source=chatgpt.com

[13] Kakcent. (2023, January 19). *ចំណូល*. Retrieved February, 05 2025 from https://www.kakcent.com/3-types-of-income-you-should-have//

[14] Library of Royal University of Law and Economic. គណនេយ្យ. (2020, Jun 20). អ្វីជាចំណូល? Retrieved February, 05 2025 from https://www.facebook.com/photo.php?fbid=4297751153583315&id=1149435801748215&set=a.1149438368414625&locale=km_KH

សិក្សា ឬសេវាខ្លះត្រូវបានធ្វើកិច្ចសន្យានៃ ការបង់ចំណូលតាមភាគរយនៃការអនុវត្តការងារ ឬការផ្តល់សេវាកម្មរួចហើយទទួលបានចំណូល។

➢ការប្រាក់ពីធនាគារគឺជាចំណូលដែលបានពីធនាគារបានពីគណនីសន្សំ គណនីមានកាលកំណត់ដែលទទួលបានអត្រាការប្រាក់ផ្សេងគ្នា។

➢ការវិនិយោគផ្សេងៗ គឺជាចំណូលដែលស្ថាប័នបានយកប្រាក់ចំណេញ ពីស្ថាប័នទៅវិនិយោគដើម្បីបានប្រាក់ចំណូលផ្សេងទៀត។

➢អំណោយ ឬការបរិច្ចាក គឺជាចំណូលរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងសហគមន៍។

➢ការជួល គឺជាចំណូលដែលបានពីការជួលអគារ ទ្រព្យសកម្មផ្សេងៗ និងចំណូលផ្សេងៗទៀត[15]។

## ២.៣ នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន

### ២.៣.១ និយមន័យនៃនីតិវិធី

➢នីតិវិធី គឺជាបែបបទផ្លូវការក្នុងការធ្វើអ្វីមួយដោយសេរី នៃសកម្មភាពដែលប្រព្រឹត្តិទៅតាមលំដាប់លំដោយមួយចំនួន[16]។

➢នីតិវិធី គឺជាវិធីដែលតុលាការប្រើប្រាស់ ដើម្បីចាត់ចែងរឿងក្តីតាំងពីដើមរហូតដល់ចប់[17]។

➢នីតិវិធី ជារបៀបចាត់ការដែលច្បាប់បានកំណត់[18]។

➢នីតិវិធី ជាវិធីដែលតុលាការប្រើប្រាស់ដើម្បីចាត់ចែងរឿងក្តីតាំងពីដើមរហូតដល់ចប់[19]។

### ២.៣.២ ប្រវត្តិនៃនីតិវិធី

ប្រវត្តិនៃនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយក្រុមហ៊ុន មានការផ្លាស់ប្តូរយ៉ាងច្រើនស្របតាមការអភិវឌ្ឍទំនៀមទម្លាប់នៃសេដ្ឋកិច្ច និងបច្ចេកវិទ្យា។ ការគ្រប់គ្រងហិរញ្ញវត្ថុបានកំណត់សំខាន់ក្នុងការប្រតិបត្តិការអាជីវកម្មនិងជាកត្តាសំខាន់សម្រាប់ការរីកចម្រើនរបស់ក្រុមហ៊ុន។ នីតិវិធីនេះបានបង្កើតឡើងក្នុងបរិបទនៃការផ្តោតលើការអភិវឌ្ឍ និងការត្រួតពិនិត្យធនធានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដើម្បីអាចគ្រប់គ្រងការចំណាយ និងចំណូលឱ្យមានប្រសិទ្ធភាព។

➢សម័យចាប់ផ្តើមនៃការគ្រប់គ្រងចំណូលនិងចំណាយ

ក្នុងអតីតកាល មុនការអភិវឌ្ឍនៃប្រព័ន្ធហិរញ្ញវត្ថុគ្រប់គ្រងទំនាក់ទំនងអាជីវកម្មគឺសាមញ្ញជាងនេះ។

[15] រៀបរៀងដោយនិស្សិត អ៊ុក ភារិត (២០២១) វិទ្យាស្ថានវ៉ាន់ដារបាយការណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតឈ្មោះ ទំព័រទី៧

[16] YouTube. The SUN Dictionary. (2024, February 11). *នីតិវិធី (Procedure).* Retrieved February, 05 2025 from https://www.youtube.com/watch?v=gz4W4j46zjM

[17] រៀបរៀងដោយនិស្សិត ជា លីនណា, ប៉ែន ចាន់ណាក់, ហុង ស្រីស, វួន សាវ៉ាន់, ណុង ម៉េងលាភ. (2022). *ការគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន ខ្មែរប៊ែវើរីជីស.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី១៩. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៧. ៣២ទំព័រ. ភ្នំពេញ។

[18] រៀបរៀងដោយនិស្សិត ឃី សៀវម៉ី, សេង ដារីន, ប៊ិន ដាវ៉េ, អុល ធារ៉ា. (2022). *ការគ្រប់គ្រងចំណូល-ចំណាយរបស់ក្រុមហ៊ុន អាយ៉ាប្រោតអ៊ីនជីណេសិនណល ភីធីអ៊ី អិលធីឌី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ ជំនាន់ទី១៩. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៦. ៣៣ទំព័រ. ភ្នំពេញ។

[19] The American Historical Association (AHA). (2019, November 10). *ប្រវត្តិនៃនីតិវិធី.* Retrieved February, 05 2025 from https://www.historians.org/?s=history++procedure

ក្រុមហ៊ុនបានគ្រប់គ្រងចំណូល និងចំណាយតាមរយៈការជួញដូរ និងប្រើប្រាស់ការត្រួតពិនិត្យដ៏សាមញ្ញដែលមិនមានបច្ចេកវិទ្យា។ នៅក្នុងកម្រិតអាជីវកម្មធម្មតា ការត្រួតពិនិត្យសាច់ប្រាក់ ក៏មិនត្រឹមត្រូវនឹងការវិភាគជាក់លាក់សម្រាប់ការអភិវឌ្ឍរយៈពេលវែង។

➢ការអភិវឌ្ឍនៃការគ្រប់គ្រងហិរញ្ញវត្ថុ

នៅក្នុងសម័យស្រដៀងនឹងការអភិវឌ្ឍឧស្សាហកម្ម និងការកំណត់ប្រព័ន្ធគ្រប់គ្រងធនធានហិរញ្ញវត្ថុ ការគ្រប់គ្រងចំណូល និងចំណាយក្រុមហ៊ុនមានការពង្រឹងជាមួយនឹងការបញ្ចូលគ្រប់គ្រងលើប្រព័ន្ធហិរញ្ញវត្ថុដែលមានការប្រើប្រាស់វិធីសាស្ត្រប្រកបដោយជំនាញ និងការវិភាគលម្អិត។ នេះអាចនាំឱ្យមានការពិចារណារឿងមូលដ្ឋាននៃប្រាក់ចំណូលជាក់ស្តែង និងការត្រួតពិនិត្យលើការចំណាយជាក់លាក់។

➢ការអភិវឌ្ឍបច្ចេកវិទ្យានិងការត្រួតពិនិត្យប្រព័ន្ធ

ជាមួយនឹងការផ្លាស់ប្តូរនៃបច្ចេកវិទ្យា និងបរិបទអាជីវកម្ម បច្ចេកវិទ្យាអ្នករៀបចំប្រព័ន្ធធនធានហិរញ្ញវត្ថុបានចូលរួមគាំទ្របន្ថែមនូវការគ្រប់គ្រងដែលមានប្រសិទ្ធភាព។ ការអភិវឌ្ឍនៃកម្មវិធីហិរញ្ញវត្ថុ និងការត្រួតពិនិត្យបានជួយឱ្យក្រុមហ៊ុនធ្វើការតាមដាន និងគ្រប់គ្រងបច្ចេកវិទ្យានេះសម្រាប់ការត្រួតពិនិត្យចំណូល និងចំណាយក្នុងរយៈពេលដែលបានកំណត់។

➢ការរីកចម្រើននៃគ្រប់គ្រងការវិនិយោគ

ក្រុមហ៊ុនបានយកចិត្តទុកដាក់ទៅលើការត្រួតពិនិត្យការវិនិយោគ ដើម្បីធានាថាហិរញ្ញវត្ថុដែលមានត្រូវបានគ្រប់គ្រង ក្នុងវិស័យដែលមានប្រសិទ្ធភាព និងអាចជួយក្រុមហ៊ុនសម្រេចបានគោលបំណងសេដ្ឋកិច្ចរបស់ខ្លួន។ បច្ចេកវិទ្យាអាចនាំឱ្យការពិចារណានៃការវិនិយោគល្អបំផុត ហើយធ្វើឱ្យក្រុមហ៊ុនអាចធ្វើការអនុវត្តន៍គោលនយោបាយដទៃៗក្នុងការលក់ផលិតផល និងសេវាកម្មក្នុងតម្លៃដែលសមរម្យ។

➢ប្រព័ន្ធគ្រប់គ្រងចំណូលនិងចំណាយសម័យទំនើប

នៅក្នុងសម័យទំនើបក្រុមហ៊ុនកាន់តែប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដូចជា កម្មវិធីវាយតម្លៃហិរញ្ញវត្ថុ និងការវិភាគធនធាន ដើម្បីជួយគ្រប់គ្រងចំណូល និងចំណាយឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តន៍ ត្រួតពិនិត្យការចំណាយក្នុងរយៈពេលពិចារណាប្រកបដោយសមិទ្ធផលសម្រាប់ក្រុមហ៊ុន និងអ្នកវិនិយោគ។

➢ស្ថាបត្យកម្មការគ្រប់គ្រង និងការផ្លាស់ប្តូរប្រព័ន្ធ

ប្រព័ន្ធនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយក្រុមហ៊ុនមានការផ្លាស់ប្តូរតាមរយៈការកំណត់យ៉ាងច្បាស់លាស់នូវគោលការណ៍ និងលក្ខណៈវិសេសដែលធ្វើឱ្យប្រព័ន្ធសាងសង់បានយ៉ាងមានប្រសិទ្ធភាព និងមានសិទ្ធិអនុវត្តតាមការកំណត់ជាក់លាក់ជាមួយនឹងតម្រូវការជាក់លាក់របស់ក្រុមហ៊ុន។

ប្រវត្តិនៃនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយក្រុមហ៊ុនបានបង្ហាញពីការប្រែប្រួល និងការកែលម្អ ដ៏សំខាន់ក្នុងការពង្រឹងសមត្ថភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍអាជីវកម្មបដើម្បីសម្រេចបានគោលបំណងសេដ្ឋកិច្ចនិងអាជីវកម្មរបស់ក្រុមហ៊ុន[20]។

[20] Resear chgate. Laurens Walker. (1978, May 20). *ទ្រឹស្តីនៃនីតិវិធី*. Retrieved February, 07 2025 from https://www.researchgate.net/publication/254558157_A_Theory_of_Procedure

**២.៣.៣ ទ្រឹស្តីនៃនីតិវិធី**

ទ្រឹស្តីនៃនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយក្រុមហ៊ុនគឺការប្រើប្រាស់នយោបាយ និងការវិភាគយ៉ាងប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ រួមទាំងការត្រួតពិនិត្យចំណូល និងចំណាយឱ្យមានប្រសិទ្ធភាព និងអនុវត្តតាមគោលការណ៍ដើម្បីធានាថាក្រុមហ៊ុនអាចប្រើប្រាស់ធនធានទាំងអស់បានយ៉ាងសម្រាប់ឧត្តមភាពសេដ្ឋកិច្ច និងស្ថេរភាព។ ទ្រឹស្តីនៃនីតិវិធីនេះ មានគោលបំណងដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងបង្កើនសមត្ថភាពក្រុមហ៊ុនឱ្យមានការប្រកួតប្រជែង និងមានការរីកចម្រើន។

➢ទ្រឹស្តីអំពីការត្រួតពិនិត្យចំណូល

ការត្រួតពិនិត្យចំណូល គឺជាមុខងារដែលមានសារៈសំខាន់ ក្នុងការពិចារណាលើបរិមាណចំណូល និងផលិតផល។ ទ្រឹស្តីនេះផ្តោតទៅលើការប្រើប្រាស់គ្រប់គ្រងយ៉ាងត្រឹមត្រូវដើម្បីអាចមានចំណូលល្អ និងធានាថាក្រុមហ៊ុនអាចបញ្ចេញផលិតផល និងសេវាកម្មដោយសមរម្យនិងតម្រូវការតាមទីផ្សារ។ វាជួយផ្តល់ការពិចារណាជាក់លាក់ចំពោះប្រភពចំណូលនិងអ្វីដែលអាចធ្វើបានដើម្បីបង្កើនចំណូលក្នុងរយៈពេលវែង។

➢ទ្រឹស្តីអំពីការគ្រប់គ្រងចំណាយ

ទ្រឹស្តីនេះផ្តោតទៅលើការពិចារណានិងកំណត់ចំណាយដែលពាក់ព័ន្ធនឹងការប្រតិបត្តិការក្រុមហ៊ុន។ វាជួយជម្រុញឱ្យក្រុមហ៊ុនពិចារណាពីការប្រើប្រាស់ធនធានសម្រាប់កំណត់ចំណាយ និងការអនុវត្តប្រព័ន្ធត្រួតពិនិត្យយ៉ាងសមស្រប។ តាមទ្រឹស្តីនេះ ក្រុមហ៊ុនត្រូវតែបង្ហាញពីការអនុវត្តន៍ការចំណាយដែលអាចកាត់បន្ថយការបង់ប្រាក់ជាច្រើនព្រោះវាជួយឱ្យក្រុមហ៊ុនរក្សាទុកប្រាក់សម្រាប់ការវិនិយោគ ឬការអភិវឌ្ឍខាងមុខ។

➢ទ្រឹស្តីអំពីការព្យាករណ៍ហិរញ្ញវត្ថុ និងការវិភាគ

ការព្យាករណ៍ហិរញ្ញវត្ថុ និងការវិភាគផ្តល់ឱ្យក្រុមហ៊ុនការយល់ដឹងដល់អនាគតដូចជាការព្យាករណ៍លើការចំណាយនិងចំណូលដែលអាចមាន ឬត្រូវការអនុវត្តន៍សម្រាប់ការវិនិយោគ។ វាជាកត្តាដ៏សំខាន់ក្នុងការធានាថា អ្នកគ្រប់គ្រងហិរញ្ញវត្ថុមានការពិចារណាជាក់លាក់ និងធានាថាក្រុមហ៊ុនអាចរៀបចំការប្រតិបត្តិការយ៉ាងមានប្រសិទ្ធភាពតាមការព្យាករណ៍របស់ខ្លួន។

➢ទ្រឹស្តីអំពីភាពទៀងទាត់ និងភាពត្រួតពិនិត្យ

ទ្រឹស្តីនេះ បង្ហាញពីភាពសំខាន់នៃការអនុវត្តន៍នីតិវិធីដែលមានការត្រួតពិនិត្យជាប់គ្នា និងភាពត្រឹមត្រូវសម្រាប់ការគ្រប់គ្រងសាច់ប្រាក់ឱ្យមានភាពច្បាស់លាស់។ ក្រុមហ៊ុន ត្រូវតែពិនិត្យប្រតិបត្តិការនីតិវិធីគ្រប់គ្រងចំណូល និងចំណាយរបស់ខ្លួនរៀងរហូត ដើម្បីសម្របសម្រួលនូវការអនុវត្តតាមលក្ខខណ្ឌដែលត្រូវការ និងមានភាពល្អប្រសើរឡើង។

➢ទ្រឹស្តីអំពីកំណត់ប្រសិទ្ធភាព និងស្ថេរភាព

តាមទ្រឹស្តីនេះ ការគ្រប់គ្រងចំណូល និងចំណាយអាចអភិវឌ្ឍន៍ជាមួយនឹងការបង្ហាញពីប្រសិទ្ធភាព និងស្ថេរភាពក្នុងការអនុវត្តន៍ផែនការអាជីវកម្ម។ ក្រុមហ៊ុនត្រូវតែបង្កើនការចំណាយក្នុងតំបន់ដែលមានសក្តានុពលធ្វើឱ្យការងាររបស់ក្រុមហ៊ុនមានប្រសិទ្ធភាពនិងអាចប្រើប្រាស់ធនធានបានយ៉ាងល្អ។

➢ទ្រឹស្តីអំពីការពង្រឹងការផ្តល់សេវាកម្មហិរញ្ញវត្ថុ

ក្រុមហ៊ុនអាចប្រើប្រាស់ទ្រឹស្តីនេះដើម្បីធានាថាអ្នកវិនិយោគ និងអ្នកបង់ប្រាក់ទំនាក់ទំនងនឹងក្រុមហ៊ុន នៅតែមានភាពសុខស្រួលក្នុងការធ្វើការប្រកួតប្រជែង។ វាគាំទ្រអំពីការផ្តល់ជូនសេវាកម្មដែលមានការពង្រឹង ទៅកាន់ការចំណាយ និងការវិនិយោគសមរម្យ[21]។

**២.៣.៤ មុខងារនៃនីតិវិធី**

មុខងារនៃនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុនគឺមានសារៈសំខាន់ក្នុងការធ្វើឱ្យក្រុមហ៊ុនមានការត្រួតពិនិត្យលើធនធានហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រាក់ឱ្យមានប្រសិទ្ធភាព។ នីតិវិធីនេះអនុញ្ញាតឱ្យក្រុមហ៊ុនអាចគ្រប់គ្រងការចំណាយ ចំណូល និងធនធានទាំងអស់បានយ៉ាងមានប្រសិទ្ធភាព និងមានការពង្រឹងភាពសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។ នីតិវិធីគ្រប់គ្រងចំណូលនិងចំណាយមានមុខងារសំខាន់ៗ ដូចខាងក្រោមៈ

➢ការត្រួតពិនិត្យនិងគ្រប់គ្រងចំណូល

មុខងារដំបូងនៃនីតិវិធី គឺការត្រួតពិនិត្យចំណូលរបស់ក្រុមហ៊ុន។ នេះមានន័យថាគ្រប់ចំណូលគ្រប់ប្រភពត្រូវតាមដាន និងឆ្លើយតបសម្រាប់ការត្រួតពិនិត្យការចំណាយ និងដើម្បីបញ្ជាក់ថាក្រុមហ៊ុនមានចំណូលគ្រប់គ្រាន់ដើម្បីគាំទ្រការប្រតិបត្តិរបស់ខ្លួន។

➢ការកំណត់និងគ្រប់គ្រងចំណាយ

ក្រុមហ៊ុនត្រូវកំណត់ចំណាយក្នុងលក្ខណៈដែលមានការពិចារណាអំពីធនធានដែលអាចប្រើបាន។ នេះនឹងធ្វើឱ្យក្រុមហ៊ុនអាចប្រើប្រាស់ប្រាក់ត្រឹមត្រូវ និងបង្កើនការចំណាយតិចតួច ប្រសិនបើមានការត្រួតពិនិត្យលើការប្រើប្រាស់ធនធាន។

➢ការប្រមូលផ្តុំនិងវិភាគព័ត៌មានហិរញ្ញវត្ថុ

នីតិវិធីគ្រប់គ្រងចំណូល និងចំណាយត្រូវត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងការវិភាគពីប្រភពចំណូល និងចំណាយនានា ដើម្បីធានាថាក្រុមហ៊ុនកំពុងប្រើប្រាស់ធនធានដោយសមស្រប។ វាជាការអាចធ្វើការបញ្ជាក់នូវគ្រប់តុល្យភាព និងអនុវត្តតាមគោលការណ៍សេដ្ឋកិច្ច។

➢ការផ្តល់ការសម្រេចចិត្តនៅលើការវិនិយោគ

ក្រុមហ៊ុនត្រូវការត្រួតពិនិត្យចំណូល និងចំណាយ ដើម្បីធានាថាការវិនិយោគដែលប្រើប្រាស់ប្រាក់របស់ក្រុមហ៊ុន គឺមានប្រសិទ្ធភាព និងអាចនាំឱ្យមានផលប្រយោជន៍ក្នុងពេលអនាគត។

➢ការបញ្ជាក់ពីភាពទំនាក់ទំនងនៃការចំណាយ

ការត្រួតពិនិត្យនិងគ្រប់គ្រងចំណាយ និងចំណូលអាចជួយក្រុមហ៊ុនប្រើប្រាស់ធនធានល្អជាងមុន ដោយការបង្ហាញ ពីទំនាក់ទំនងរបស់ចំណាយ និងចំណូលដែលជា កត្តាសំខាន់សម្រាប់កំណត់យ៉ាងច្បាស់ថាគ្រប់គ្រង ប្រព័ន្ធហិរញ្ញវត្ថុធ្វើការប្រាកដថាសមស្របនឹងអាជីវកម្ម។

---

[21] Resear chgate. Laurens Walker. (1978, May 20). *ទ្រឹស្តីនៃនីតិវិធី*. Retrieved February, 07 2025 from https://www.researchgate.net/publication/254558157_A_Theory_of_Procedure

➢ការផ្តល់មូលដ្ឋានសម្រាប់ការប្រតិបត្តិការត្រៀមខាងមុខនីតិវិធីនេះ អាចជួយក្រុមហ៊ុនបម្រើការពិចារណាពីការត្រៀមសម្រាប់ប្រតិបត្តិការនាពេលអនាគតដោយការទទួលស្គាល់នូវការព្យាករណ៍អនាគតចំពោះចំណូល និងចំណាយដែលមានការត្រួតពិនិត្យយ៉ាងតឹងរឹង[22]។

[22] Microsoft. (2021, September 15). *មុខងារនៃនីតិវិធី*. Retrieved February, 07 2025 from https://learn.microsoft.com/en-us/dotnet/visual-basic/programming-guide/language-features/procedures/function-procedures

# ជំពូកទី៣
# នីតិវិធីក្នុងការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុន
# អរ អិម អេ (ខេមបូឌា) ម.ក

## ៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន

នៅក្នុងប្រទេសមានរយៈពេលជាង ៣ ទស្សវត្ស ដោយបានចូលប្រទេសកម្ពុជាជាលើកដំបូងក្នុងឆ្នាំ ១៩៩២ ហើយចាប់ផ្តើមជាអ្នកផ្តល់ទំនិញដល់សហគ្រាសអភិវឌ្ឍន៍ពាណិជ្ជកម្ម និងជំនួយក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងផ្នែកដឹកជញ្ជូន។ ក្រុមខ្លួនបានទៅជាមួយចលនារបស់អង្គការសហប្រជាជាតិនៅពេលនោះដូច្នេះនៅពេលដែលអង្គការសហប្រជាជាតិមកកម្ពុជាក្នុងនាមអ៊ុនតាក់ អាជីវកម្មនេះត្រូវបានចាប់ផ្តើមដើម្បីបម្រើដល់ចលនាអង្គការសហប្រជាជាតិនោះ។

យូរៗទៅ អាជីវកម្មបានឃើញនូវឱកាសបន្តសម្រាប់កំណើនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ ហើយចាប់តាំងពីពេលនោះមកបានពង្រីក និងល្បីល្បាញបំផុតសម្រាប់វត្តមានរបស់ខ្លួននៅក្នុងឧស្សាហកម្ម រថយន្ត កសិកម្ម និងឧបករណ៍ធន់ធ្ងន់ អាហារ និងភេសជ្ជៈ និងច្រើនទៀត។

សព្វថ្ងៃនេះ យើងមានបុគ្គលិកជាង៤,០០០នាក់ដែលធ្វើការងារឱ្យពួកយើងហើយចំណូលរបស់យើង គឺជាង ៥០០ លានដុល្លារអាមេរិក ។

លោក ងនសាំង បានពន្យល់ថា ទម្រង់អាជីវកម្មដ៏ទូលំទូលាយរបស់ RMA Cambodia រួមមាន៖

- ➢រថយន្តម៉ាកដូចជា ៖ Ford, Range Rover, Jaguar, រថយន្តដឹកទំនិញ Fuso ។
- ➢ឧបករណ៍កសិកម្ម៖ ត្រាក់ទ័រ John Deere និងអ្នកច្រូតកាត់។
- ➢សំណង់៖ ក្រុមហ៊ុន RMA មានក្រុមហ៊ុនចែកចាយ Fuso ម៉ាស៊ីនស៊ីម៉ង់ត៍ JCB និងម៉ាស៊ីនមកពីប្រទេសឥណ្ឌា ហើយក៏មានលក់គ្រឿងសំណង់។ ក្រុមហ៊ុនក៏ចូលរួមក្នុងការត្រួតពិនិត្យ និងវាយតម្លៃសំណង់ (M&E) ផងដែរ។
- ➢អាជីវកម្មជួល៖ RMA មានសិទ្ធិផ្តាច់មុខសម្រាប់ Avis Budget Group ដែលជាអាជីវកម្មជួលដ៏ធំបំផុតនៅក្នុងប្រទេសកម្ពុជាសម្រាប់រថយន្ត និងឧបករណ៍ផ្សេងទៀត។
- ➢អាហារ និងភេសជ្ជៈ (F&B)៖ យីហោឈានមុខគេដូចជា Pizza Company, Dairy Queen, Krispy Kreme និងច្រើនទៀត។
- ➢បដិសណ្ឋារកិច្ច៖ ក្រុមហ៊ុន RMA ថ្មីៗនេះបានផ្លាស់ប្តូរចូលទៅក្នុងអាជីវកម្មសណ្ឋាគារ និងជាម្ចាស់ FCC Angkor ខេត្តសៀមរាប។

RMA Group គឺជាដៃគូនៃជម្រើសសម្រាប់រថយន្ត គ្រឿងបរិក្ខារ សេវាកម្ម និងម៉ាកម្ហូបអាហារឈានមុខគេ ហើយបានផ្តល់ការងារដល់មនុស្សជាង ៨,០០០ នាក់ដែលមានលទ្ធភាពទទួលបានទូទាំងពិភពលោកក្នុង ១៤ ប្រទេស។ នៅចុងទសវត្សឆ្នាំ ១៩៨០ ក្រុមហ៊ុនបានក្លាយជាអ្នកផ្តល់ទំនិញសម្រាប់ជំនួយ និងការអភិវឌ្ឍ និងសហគ្រាសពាណិជ្ជកម្មក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងភស្តុភារ ដោយផ្គត់ផ្គង់រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអ្នកម៉ៅការឯកជន។ វាបានចាប់ដៃគូជាមួយ OEMs រថយន្ត និងឧបករណ៍ឈានមុខគេ

ក៏ដូចជាអតិថិជនកងនាវា ហើយបានបង្កើតបណ្តាញលក់រាយ និងមជ្ឈមណ្ឌលផលិត និងចែកចាយដ៏ល្អឥតខ្ចោះ។

ប្រតិបត្តិការយានយន្តរបស់ RMA រួមមានការផលិតយានយន្ត ការកែប្រែយានយន្តពិសេស ការចែកចាយយានយន្ត និងឧបករណ៍ ការលក់ និងក្រោយពេលលក់ ការចែកចាយគ្រឿងបន្លាស់ ការគ្រប់គ្រងកងនាវា និងសេវាមជ្ឈមណ្ឌល។ ផ្នែកកសិកម្ម និងបរិក្ខារធន់ធ្ងន់ធ្វើការលក់ ការចែកចាយ និងក្រោយពេលលក់សម្រាប់ John Deere, JCB និង TCM ក្នុងចំណោមអ្នកផ្សេងទៀត ខណៈដែល Asia Vehicle Rental Franchisees for Avis Budget ផ្តល់ការជួលរថយន្ត និងឧបករណ៍។ រោងចក្រផលិត និងកែប្រែរថយន្តមានទីតាំងនៅប្រទេសថៃ ឌូបៃ ទួរគី អាហ្វ្រិកខាងត្បូង និងអូស្ត្រាលី ហើយកន្លែងដំឡើងរថយន្តមានទីតាំងនៅកម្ពុជា និងមីយ៉ាន់ម៉ា។ អាជីវកម្មផ្សេងទៀតស្ថិតនៅក្នុងផ្នែកសេវាកម្មហិរញ្ញវត្ថុ វិស្វកម្ម និងផ្នែកបដិសណ្ឋារកិច្ច។ នៅក្នុងការបណ្តាក់ទុនរួមគ្នាជាមួយធនាគារខាងត្បូងប៉ាស៊ីហ្វិក BSP Finance ផ្តល់ដំណោះស្រាយផ្នែកហិរញ្ញវត្ថុ និងយានយន្តដល់អតិថិជនក្នុងប្រទេសកម្ពុជា និងឡាវ។ Comin Asia ផ្តល់សេវាកម្មកិច្ចសន្យា MEP សម្រាប់បរិស្ថានដែលបានសាងសង់ និងដំណោះស្រាយថាមពលកកើតឡើងវិញ។ Express Food Group គឺ យីហោអាហារអន្តរជាតិក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ហើយបើកភោជនីយដ្ឋានជាងមួយរយ និងសេវាកម្មដឹកជញ្ជូនអាហារព្រមទាំងភោជនីយដ្ឋានអាកាសយានដ្ឋានក្នុងប្រទេសកម្ពុជា និងអាកាសយានដ្ឋាន Changi ប្រទេសសិង្ហបុរី[23]។

**និមិត្តសញ្ញាក្រុមហ៊ុន**




[23] TECH NEWS. (2023, April 25). *ប្រវត្តិរបស់ក្រុមហ៊ុន អ អិម អេ ខេមបូឌា ម.ក (RMA Cambodia Plc.)*. Retrieved February, 07 2025 from https://tech.sabay.com.kh/article/1344579

### ៣.១.២ ទីតាំងរបស់ក្រុមហ៊ុន

ផ្ទះលេខ ២៧ ផ្លូវ១៣៤ ប្រអប់សំបុត្រ ៥៥ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

### ៣.១.៣ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន




### ៣.១.៤ គោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន

គោលនយោបាយគណនេយ្យរបសក្រុមហ៊ុន RMA (CAMBODIA) PLC គឺអាចមានភាពប្លែកបន្តិចពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយ ដោយផ្អែកលើអាជីវកម្មនិងគោលបំណងរបស់ក្រុមហ៊ុននោះ។ ទោះបីជាយ៉ាងណាក៏ដោយ គោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន RMA (CAMBODIA) PLC យ៉ាងហោចណាស់អាចផ្តោតទៅលើប្រព័ន្ធ និងដំណើរការទូទៅដែលអាចដំណើរការបានជោគជ័យនៃគណនេយ្យ។ មូលដ្ឋាននៃគោលនយោបាយនេះអាចរួមបញ្ចូលចំណុចដូចជា៖

➤ការគ្រប់គ្រងប្រាក់ចំណូល និងចំណាយដើម្បីធានាថាក្រុមហ៊ុនមានការគ្រប់គ្រងហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព។

➤ការបញ្ជាក់ពីប្រព័ន្ធគណនេយ្យ និងវិញ្ញាសាផ្សេងៗ ការផ្លាស់ប្តូរ និងបច្ចេកវិទ្យាថ្មីៗអាចបង្ហាញពីការផ្លាស់ប្តូរនៅក្នុងគោលនយោបាយ។

